ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា
លេខ:........០០៦..........គ.ល.ក.ប្រក

# ប្រកាស
# ស្តីពី
# នីតិវិធី បែបបទ និងលក្ខខណ្ឌនៃការផ្តល់និងការបន្តសុពលភាព
# អាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣១ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៦៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០២ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ស្តីពីការពិន័យអន្តរការណ៍ចំពោះបទល្មើសទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
- យោងតាមការសម្រេចរបស់គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា នាសម័យប្រជុំលើកទី៥ អាណត្តិទី១ នាថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២២

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ កំណត់អំពីនីតិវិធី បែបបទ និងលក្ខខណ្ឌនៃការផ្តល់និងការបន្តសុពលភាពអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ ដើម្បីធានាបាននូវការគ្រប់គ្រងបុគ្គលិកពិសេសកាស៊ីណូ និងរួមចំណែកក្នុងការគ្រប់គ្រងប្រតិបត្តិការកាស៊ីណូ ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយ។

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះបុគ្គលិកពិសេសកាស៊ីណូ និងអ្នកកាន់កាប់អាជ្ញាបណ្ណកាស៊ីណូ និង/ឬប្រតិបត្តិករកាស៊ីណូ ដែលប្រតិបត្តិការកាស៊ីណូនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## សមត្ថកិច្ចក្នុងការផ្តល់អាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ

**ប្រការ៣.-**

**គ.ល.ក.** មានសមត្ថកិច្ចក្នុងការផ្តល់អាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ។

ប្រធាន **គ.ល.ក.** អាចប្រគល់សិទ្ធិជូនអគ្គលេខាធិការ **គ.ល.ក.** ក្នុងការផ្តល់ និងការបន្តសុពលភាពអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ។

## ជំពូកទី៣

## នីតិវិធី បែបបទ និងលក្ខខណ្ឌនៃការផ្តល់និងការបន្តសុពលភាព អាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ

**ប្រការ៤.-**

អាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ ត្រូវបានកំណត់ជា ២ (ពីរ) ប្រភេទ ដូចខាងក្រោម៖

១. អាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ ប្រភេទ "ក" សម្រាប់បុគ្គលដែលមានមុខតំណែងណាមួយ ឬមុខតំណែងប្រហាក់ប្រហែល ដូចខាងក្រោម៖

- ប្រធាន/អគ្គនាយក នាយកប្រតិបត្តិ នាយកហិរញ្ញវត្ថុ នាយកបច្ចេកទេស នាយកកាស៊ីណូ នាយកតុល្បែង នាយកស្លតម៉ាស៊ីន
- អគ្គទីប្រឹក្សា/ទីប្រឹក្សា ជំនួយការប្រធាន/អគ្គនាយក ឬជំនួយការអ្នកកាន់កាប់អាជ្ញាបណ្ណកាស៊ីណូ និង/ឬប្រតិបត្តិករកាស៊ីណូ
- អ្នកគ្រប់គ្រងកាស៊ីណូ (Casino Manager) អ្នកគ្រប់គ្រងសវនកម្មកាស៊ីណូ (Casino Audit Manager) អ្នកគ្រប់គ្រងតុល្បែង (Pit Manager) អ្នកគ្រប់គ្រងស្លតម៉ាស៊ីន (Slot Manager) អ្នកគ្រប់គ្រងភ្ញៀវល្បែងកាស៊ីណូ/ភ្ញៀវល្បែងវីអាយភី (Casino Host Manager/VIP Host Manager) អ្នកគ្រប់គ្រងរង្វាន់ ឬពិន្ទុសម្រាប់ភ្ញៀវល្បែង (Reward Manager/Casino Service Manager) អ្នកគ្រប់គ្រងខេច ឬទូប្រាក់ (Cage/Vault Manager) អ្នកគ្រប់គ្រងឥណទាន (Credit Manager) អ្នកគ្រប់គ្រងទម្លាក់និងរាប់ (Drop&Count Manager/Casino

Controller) អ្នកគ្រប់គ្រងសន្តិសុខក្នុងកាស៊ីណូ (Casino Security Manager) អ្នកគ្រប់គ្រងឧបករណ៍តាមដាន (Surveillance Manager) អ្នកគ្រប់គ្រងបច្ចេកទេសស្លតម៉ាស៊ីននិង/ឬឧបករណ៍ល្បែងមេកានិក អេឡិចត្រូមេកានិក ឬអេឡិចត្រូនិក (Slot/EGM Tech Manager) អ្នកគ្រប់គ្រងបច្ចេកទេសសម្រាប់ឧបករណ៍តាមដាន ប្រព័ន្ធគ្រប់គ្រងស្លតម៉ាស៊ីនឬឧបករណ៍ល្បែងមេកានិក អេឡិចត្រូមេកានិក ឬអេឡិចត្រូនិក (Technical Manager for Surveillance Equipment, Slot Management System or EGM and/or Electronic Equipment System Monitoring)

- អ្នកគ្រប់គ្រងតុល្បែងតាមវេន (Pit Shift Manager) អ្នកគ្រប់គ្រងស្លតម៉ាស៊ីនតាមវេន (Slot Shift Manager) អ្នកគ្រប់គ្រងខេច ឬទូប្រាក់តាមវេន (Cage/Vault Shift Manager) អ្នកគ្រប់គ្រងសន្តិសុខក្នុងកាស៊ីណូតាមវេន(Security Shift Manager) អ្នកគ្រប់គ្រងឧបករណ៍តាមដានតាមវេន (Surveillance Shift Manager)។

២. អាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូប្រភេទ "ខ" សម្រាប់បុគ្គលដែលមានមុខតំណែងណាមួយ ឬមុខតំណែងប្រហាក់ប្រហែល ដូចខាងក្រោម៖

- សវនករបស់កាស៊ីណូ (Casino Auditor) គណនេយ្យករកាស៊ីណូ (Casino Accountant) អ្នកត្រួតពិនិត្យតុល្បែង (Pit Supervisor/Casino Floor Supervisor) អ្នកត្រួតពិនិត្យឌៀលល័រល្បែង (Game Dealer Supervisor) អ្នកត្រួតពិនិត្យស្លតម៉ាស៊ីន (Slot Supervisor) អ្នកត្រួតពិនិត្យឧបករណ៍ល្បែងមេកានិក ឬអេឡិចត្រូមេកានិក ឬអេឡិចត្រូនិក (EGM Supervisor) អ្នកត្រួតពិនិត្យភ្ញៀវល្បែងកាស៊ីណូ/ភ្ញៀវល្បែងវីអាយភី(Casino Host Supervisor/VIP Host Supervisor) អ្នកត្រួតពិនិត្យរង្វាន់ឬពិន្ទុសម្រាប់ភ្ញៀវល្បែង (Rewards Supervisor) អ្នកត្រួតពិនិត្យខេចឬទូប្រាក់ (Cage/Vault Supervisor) អ្នកត្រួតពិនិត្យមេនបេងឃី (Main Banker Supervisor) អ្នកត្រួតពិនិត្យអ្នកគិតលុយនៅខេច (Cage Cashier Supervisor) អ្នកត្រួតពិនិត្យឥណទាន (Credit Supervisor), អ្នកត្រួតពិនិត្យទម្លាក់និងរាប់ (Drop & Count Supervisor) អ្នកត្រួតពិនិត្យសន្តិសុខនៅ ក្នុងកាស៊ីណូ (Security Supervisor) អ្នកត្រួតពិនិត្យឧបករណ៍តាមដាន (Surveillance Supervisor) អ្នកត្រួតពិនិត្យបច្ចេកទេសស្លតម៉ាស៊ីន ឬឧបករណ៍ល្បែងមេកានិក អេឡិចត្រូមេកានិក ឬអេឡិចត្រូនិក (Slot/EGM Tech Supervisor) អ្នកត្រួតពិនិត្យបច្ចេកទេសសម្រាប់ឧបករណ៍តាមដាន ប្រព័ន្ធគ្រប់គ្រងស្លតម៉ាស៊ីន ឬឧបករណ៍ល្បែង មេកានិក អេឡិចត្រូមេកានិក ឬអេឡិចត្រូនិក (Technical Supervisor for Surveillance Equipment, Slot Management System or EGM and/or Electronic Equipment System Monitoring)
- ឌៀលល័រល្បែង (Games Dealer) អ្នកប្រចាំការនៅស្លតម៉ាស៊ីន (Slot Attendant) អ្នកប្រចាំការឧបករណ៍ល្បែងមេកានិក អេឡិចត្រូមេកានិក ឬអេឡិចត្រូនិក (EGM Attendant) បុគ្គលិកទទួលភ្ញៀវល្បែងកាស៊ីណូ/ភ្ញៀវល្បែងវីអាយភី(Casino Host Officer/VIP Host Officer) អ្នកផ្តល់រង្វាន់ ឬពិន្ទុសម្រាប់ភ្ញៀវល្បែង (Reward Officer) អ្នកគិតលុយនៅខេច (Cage Cashier) មេនបេងឃី (Main Banker) អ្នកកត់ត្រា ឬប្រមូលឥណទាន (Credit/Collection Clerk) អ្នកទទួលបន្ទុកទម្លាក់និងរាប់ (Drop & Count Team

Member) បុគ្គលិកសន្តិសុខក្នុងកាស៊ីណូ (Security Officer) អ្នកប្រតិបត្តិការឧបករណ៍តាមដាន (Surveillance Officer/Operator) អ្នកបច្ចេកទេសស្លតម៉ាស៊ីន ឬឧបករណ៍ល្បែងមេកានិក អេឡិចត្រូមេកានិក ឬអេឡិចត្រូនិក (Slot/EGM Technician) អ្នកបច្ចេកទេសសម្រាប់ឧបករណ៍តាមដាន ប្រព័ន្ធគ្រប់គ្រងស្លតម៉ាស៊ីន ឬឧបករណ៍ល្បែង មេកានិក អេឡិច-ត្រូមេកានិក ឬអេឡិចត្រូនិក (Technician for Surveillance Equipment, Slot Management System or EGM and/or Electronic Equipment System Monitoring)។

**ប្រការ៥ ._**

អ្នកកាន់កាប់អាជ្ញាបណ្ណកាស៊ីណូ និង/ឬប្រតិបត្តិករកាស៊ីណូ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ និង/ឬបន្តសុពលភាពអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ សម្រាប់បុគ្គលិករបស់ខ្លួនដែលត្រូវអនុវត្តមុខងារជាបុគ្គលិកពិសេសកាស៊ីណូ។

អាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ មានសុពលភាពមិនលើសពី ៣ (បី) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណ។

ចំពោះការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ អ្នកកាន់កាប់អាជ្ញាបណ្ណកាស៊ីណូ និង/ឬប្រតិបត្តិករកាស៊ីណូ ត្រូវដាក់ពាក្យស្នើសុំក្នុងរយៈពេលយ៉ាងតិច ៣ (បី) ខែ មុនអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូផុតសុពលភាព។

**ប្រការ៦ ._**

ពាក្យស្នើសុំអាជ្ញាបណ្ណ និង/ឬបន្តសុពលភាពអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូទាំង ២ (ពីរ) ប្រភេទ ដូចមានចែងក្នុងប្រការ៣ នៃប្រកាសនេះ ត្រូវដាក់ជូនអគ្គលេខាធិការដ្ឋាននៃ **គ.ល.ក.** តាមទម្រង់ដែលកំណត់ដោយអគ្គលេខាធិការដ្ឋាននៃ **គ.ល.ក.** និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

១. ប្រវត្តិរូប ដោយត្រូវមានបញ្ជាក់ពីកម្រិតវប្បធម៌និងបទពិសោធន៍ និងភ្ជាប់រូបថត ៤ x ៦ ចំនួន ៣ (បី) សន្លឹក
២. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ
៣. លិខិតថ្កោលទោស ច្បាប់ដើម
៤. កិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរ
៥. ឯកសារបញ្ជាក់ពីសមត្ថភាពមុខងារដែលត្រូវអនុវត្តនៅក្នុងអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ
៦. ទិដ្ឋាការស្នាក់នៅដែលមានសុពលភាព ចេញដោយក្រសួងមហាផ្ទៃ (សម្រាប់ជនបរទេស)
៧. ប័ណ្ណការងារនិងសៀវភៅការងារ ដែលមានសុពលភាព ចេញដោយក្រសួងការងារនិងបណ្តុះ-បណ្តាលវិជ្ជាជីវៈ។

**ប្រការ៧._**

បន្ទាប់ពីទទួលបានពាក្យស្នើសុំអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ អគ្គលេខាធិការដ្ឋាននៃ **គ.ល.ក.** ត្រូវ៖

១. ធ្វើការស្រាវជ្រាវនិងសាកសួរ តាមការចាំបាច់
២. តម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំធ្វើការកែសម្រួលនិងផ្តល់នូវព័ត៌មាន ឬឯកសារពាក់ព័ន្ធបន្ថែមតាមការចាំបាច់
៣. តម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំផ្តល់ឯកសារប្រគល់សិទ្ធិ ឬឯកសារបញ្ជាក់ការយល់ព្រមពាក់ព័ន្ធចាំបាច់ ដើម្បីអាចធ្វើការស្រាវជ្រាវនិងសាកសួរ ឬដើម្បីទទួលបានព័ត៌មាន និងឯកសារពាក់ព័ន្ធ

៤. តម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំផ្តល់ភស្តុតាងចាំបាច់នានា។

ប្រសិនបើមានការផ្លាស់ប្តូរកើតឡើងពាក់ព័ន្ធនឹងព័ត៌មាននិងឯកសារ ដែលទាមទារដោយអគ្គលេខាធិការ **គ.ល.ក.** ឬពាក់ព័ន្ធនឹងផ្នែកសំខាន់ណាមួយនៃពាក្យស្នើសុំនៅមុនពេលដែលពាក្យស្នើសុំត្រូវបានទទួល ឬបដិសេធ អ្នកដាក់ពាក្យស្នើសុំត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរភ្លាមទៅអគ្គលេខាធិការដ្ឋាននៃ **គ.ល.ក.** អំពីការផ្លាស់ប្តូរនោះ។

ក្នុងអំឡុងពេលដែលពាក្យស្នើសុំកំពុងដំណើរការ អគ្គលេខាធិការ **គ.ល.ក.** អាចផ្តល់អនុសាសន៍ដល់អ្នកដាក់ពាក្យស្នើសុំឱ្យធ្វើការកែប្រែខ្លឹមសារសំខាន់ៗមួយចំនួនចំពោះពាក្យស្នើសុំរបស់ខ្លួន។

ក្នុងករណីអ្នកដាក់ពាក្យស្នើសុំដកពាក្យស្នើសុំរបស់ខ្លួនវិញ ឬពាក្យស្នើសុំត្រូវបានបដិសេធ អគ្គលេខាធិការដ្ឋាននៃ **គ.ល.ក.** មានសិទ្ធិរក្សាទុកនូវកម្រៃទម្រង់ការ។

ពាក្យស្នើសុំ ព័ត៌មាន និងឯកសារពាក់ព័ន្ធទាំងអស់ ដែលបានផ្តល់ជូនអគ្គលេខាធិការដ្ឋាននៃ **គ.ល.ក.** ត្រូវចាត់ទុកជាព័ត៌មានសម្ងាត់។

**ប្រការ៨.-**

អគ្គលេខាធិការដ្ឋាននៃ **គ.ល.ក.** ត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរអំពីសេចក្តីសម្រេចយល់ព្រម ឬបដិសេធផ្តល់អាជ្ញាបណ្ណ ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលអគ្គលេខាធិការដ្ឋាននៃ **គ.ល.ក.** ទទួលបានពាក្យស្នើសុំ និងឯកសារភ្ជាប់ពេញលេញ។

**ប្រការ៩.-**

ការប្តូរប្រភេទអាជ្ញាបណ្ណបុគ្គលិកពិសេស ឬការផ្លាស់ប្តូរមុខតំណែងដែលខុសពីប្រភេទអាជ្ញាបណ្ណដែលបុគ្គលិកពិសេសកាស៊ីណូកំពុងកាន់កាប់ អ្នកកាន់កាប់អាជ្ញាបណ្ណកាស៊ីណូ និង/ឬប្រតិបត្តិករកាស៊ីណូត្រូវបំពេញបែបបទ និងដាក់ពាក្យស្នើសុំតាមបែបបទដែលមានកំណត់ក្នុងប្រការ៥ នៃប្រកាសនេះ ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ មុនការប្តូរ ឬការកាន់មុខតំណែងថ្មីនោះ និងត្រូវបង់កម្រៃទម្រង់ការនិងកម្រៃអាជ្ញាបណ្ណដូចមានចែងក្នុងប្រការ១១ និងប្រការ១២ នៃប្រកាសនេះ។

ការផ្លាស់ប្តូរមុខតំណែងដែលស្ថិតក្នុងប្រភេទអាជ្ញាបណ្ណ ដែលបុគ្គលិកពិសេសកាស៊ីណូកំពុងកាន់កាប់ អ្នកកាន់កាប់អាជ្ញាបណ្ណកាស៊ីណូ និង/ឬប្រតិបត្តិករកាស៊ីណូ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គលេខាធិការដ្ឋាននៃ **គ.ល.ក.** ក្នុងរយៈពេលយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនការកាន់មុខតំណែងថ្មីនោះ និងត្រូវបង់កម្រៃសេវាដូចមានចែងក្នុងប្រការ១៣ នៃប្រកាសនេះ។

**ប្រការ១០.-**

អាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ ត្រូវផុតសុពលភាព ក្នុងករណីណាមួយ ដូចខាងក្រោម៖

១. អាជ្ញាបណ្ណកាស៊ីណូត្រូវបានដកហូត ឬផុតសុពលភាព

២. ការប្តូរប្រភេទអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ ដោយគិតចាប់ពីថ្ងៃដែល **គ.ល.ក.** ចេញអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូថ្មី

៣. បុគ្គលិកពិសេសកាស៊ីណូបានលាឈប់ ឬត្រូវបានបញ្ឈប់ពីការងារ

៤. បុគ្គលិកពិសេសកាស៊ីណូ ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិម

៥. អាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូត្រូវបានដកហូត ឬផុតសុពលភាព

៦. បុគ្គលិកពិសេសកាស៊ីណូបានបាត់ខ្លួន ឬអវត្តមាន ឬបានទទួលមរណភាព ដោយមានការបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច។

## ជំពូកទី៤
## កម្រៃទម្រង់ការ និងកម្រៃអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ

**ប្រការ១១.-**

អ្នកដាក់ពាក្យស្នើសុំត្រូវបង់កម្រៃទម្រង់ការសម្រាប់ការស្នើសុំអាជ្ញាបណ្ណ និង/ឬបន្តសុពលភាពអាជ្ញា-បណ្ណ ឬប្តូរប្រភេទអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ ដូចខាងក្រោម៖

១. ចំនួន ២០០.០០០ (ពីររយពាន់) រៀល សម្រាប់បុគ្គលិកពិសេសកាស៊ីណូ ចាប់ពី ១ (មួយ) នាក់ ដល់ ២៥ (ម្ភៃប្រាំ) នាក់

២. ចំនួន ៤០០.០០០ (បួនរយពាន់) រៀល សម្រាប់បុគ្គលិកពិសេសកាស៊ីណូ ចាប់ពី ២៦ (ម្ភៃប្រាំមួយ) នាក់ ដល់ ៥០ (ហាសិប) នាក់

៣. ចំនួន ៦០០.០០០ (ប្រាំមួយរយពាន់) រៀល សម្រាប់បុគ្គលិកពិសេសកាស៊ីណូ ចំនួនចាប់ពី ៥១ (ហាសិបមួយ) នាក់ ឡើងទៅ។

**ប្រការ១២.-**

អ្នកដាក់ពាក្យស្នើសុំ ត្រូវបង់កម្រៃអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូប្រចាំឆ្នាំ ដូចខាងក្រោម៖

ក.សម្រាប់បុគ្គលិកខ្មែរ៖

- ចំនួន ២០០.០០០ (ពីររយពាន់) រៀល ក្នុង ១ (មួយ)នាក់ សម្រាប់អាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ ប្រភេទ “ក”
- ចំនួន ១០០.០០០ (មួយរយពាន់) រៀល ក្នុង ១ (មួយ)នាក់ សម្រាប់អាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ ប្រភេទ “ខ”។

ខ. សម្រាប់បុគ្គលិកបរទេស៖

- ចំនួន ៨០០.០០០ (ប្រាំបីរយពាន់) រៀល ក្នុង ១ (មួយ)នាក់ សម្រាប់អាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ ប្រភេទ “ក”
- ចំនួន ៤០០.០០០ (បួនរយពាន់) រៀល ក្នុង ១ (មួយ)នាក់ សម្រាប់អាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ ប្រភេទ “ខ”។

ការបង់កម្រៃអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូប្រចាំឆ្នាំ ចំពោះការដាក់ពាក្យស្នើសុំថ្មី ត្រូវគិតស្មើនឹងពាក់កណ្តាលនៃកម្រៃអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូប្រចាំឆ្នាំ ក្នុងករណីការដាក់ពាក្យស្នើសុំនោះធ្វើឡើងក្នុងរយៈពេល ៦ (ប្រាំមួយ) ខែចុងឆ្នាំ។

**ប្រការ១៣.-**

ការស្នើសុំបោះពុម្ពអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូឡើងវិញ ឬការផ្លាស់ប្តូរមុខតំណែងក្នុងប្រភេទអាជ្ញាបណ្ណដែលបុគ្គលិកពិសេសកាស៊ីណូកំពុងកាន់កាប់ ត្រូវបង់កម្រៃសេវាចំនួន ២០០.០០០ (ពីររយពាន់) រៀល ក្នុង១ (មួយ) អាជ្ញាបណ្ណ។

**ប្រការ១៤.-**

កម្រៃដូចមានចែងក្នុងប្រការ១១ ប្រការ១២ ប្រការ១៣ ប្រាក់ពិន័យអន្តរការណ៍និងចំណាយផ្សេងទៀត ដែលមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ពាក់ព័ន្ធនឹងអាជ្ញាបណ្ណបុគ្គលិកពិសេស

កាស៊ីណូជាបន្ទុករបស់អ្នកកាន់កាប់អាជ្ញាបណ្ណកាស៊ីណូ និង/ឬប្រតិបត្តិករកាស៊ីណូ និងត្រូវបង់ចូលទៅក្នុងគណនីរបស់ **គ.ល.ក.** បន្ទាប់ពីទទួលបានប័ណ្ណបង់ប្រាក់។

អ្នកកាន់កាប់អាជ្ញាបណ្ណកាស៊ីណូ និង/ឬប្រតិបត្តិករកាស៊ីណូ ត្រូវបង់កម្រៃអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូប្រចាំឆ្នាំ មិនឱ្យលើសពីថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់។

## ជំពូកទី៥

## ភារកិច្ចរបស់អ្នកកាន់កាប់អាជ្ញាបណ្ណកាស៊ីណូ និង/ឬប្រតិបត្តិករកាស៊ីណូ

**ប្រការ១៥.-**

អ្នកកាន់កាប់អាជ្ញាបណ្ណកាស៊ីណូ និង/ឬប្រតិបត្តិករកាស៊ីណូ ត្រូវចេញប័ណ្ណសម្គាល់ខ្លួនដល់បុគ្គលិកពិសេសកាស៊ីណូទាំង ២ (ពីរ) ប្រភេទ ដោយតម្រូវឱ្យមានព័ត៌មាន ដូចខាងក្រោម៖

១. នាមករណ៍កាស៊ីណូ

២. រូបថតបុគ្គលិកពិសេសកាស៊ីណូ

៣. ឈ្មោះបុគ្គលិកពិសេសកាស៊ីណូ

៤. លេខសម្គាល់អាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូដែលចេញដោយ **គ.ល.ក.**

៥. មុខតំណែងរបស់បុគ្គលិកពិសេសកាស៊ីណូ

៦. ប្រភេទអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ។

អ្នកកាន់កាប់អាជ្ញាបណ្ណកាស៊ីណូ និង/ឬប្រតិបត្តិករកាស៊ីណូ ត្រូវតម្រូវឱ្យបុគ្គលិកពិសេសកាស៊ីណូពាក់ប័ណ្ណសម្គាល់ខ្លួនជាប់ជាប្រចាំ ក្នុងអំឡុងពេលបំពេញការងារ។

**ប្រការ១៦.-**

អ្នកកាន់កាប់អាជ្ញាបណ្ណកាស៊ីណូ និង/ឬប្រតិបត្តិករកាស៊ីណូ ត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធនឹងបុគ្គលិកកាស៊ីណូ មកអគ្គលេខាធិការដ្ឋាននៃ **គ.ល.ក.** ដូចខាងក្រោម៖

១. ផ្តល់បច្ចុប្បន្នភាពបញ្ជីឈ្មោះបុគ្គលិកកាស៊ីណូសរុប ដោយមានបញ្ជាក់ពីមុខតំណែងនិងភារកិច្ចប្រចាំត្រីមាស ដោយត្រូវផ្តល់ជូនយ៉ាងយូរត្រឹមថ្ងៃទី១០ នៃខែបន្ទាប់ និង ប្រចាំឆ្នាំ ដោយត្រូវផ្តល់ជូនយ៉ាងយូរត្រឹមថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់

២. ជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គលេខាធិការដ្ឋាននៃ **គ.ល.ក.** ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ)ថ្ងៃ ក្រោយពេលបុគ្គលិកពិសេសកាស៊ីណូត្រូវបានលាឈប់ ឬត្រូវបានបញ្ឈប់ពីការងារ

៣. ផ្តល់បច្ចុប្បន្នភាពបញ្ជីឈ្មោះបុគ្គលិកពិសេសកាស៊ីណូដែលកំពុងអនុវត្តមុខងារនិងភារកិច្ច និងបញ្ជីឈ្មោះបុគ្គលិកពិសេសកាស៊ីណូដែលត្រូវបានលាឈប់ ឬត្រូវបានបញ្ឈប់ពីការងារ ប្រចាំឆ្នាំ យ៉ាងយូរត្រឹមថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ តាមទម្រង់ដែលបានកំណត់ដោយអគ្គលេខាធិ-ការដ្ឋាននៃ **គ.ល.ក.**។

## ជំពូកទី៦

## ទោសប្បញ្ញត្តិ

**ប្រការ១៧.-**

អ្នកកាន់កាប់អាជ្ញាបណ្ណកាស៊ីណូ និង/ឬប្រតិបត្តិករកាស៊ីណូ ដែលប្រព្រឹត្តល្មើសនឹងលក្ខខណ្ឌណាមួយដែលកំណត់ដោយប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មរដ្ឋបាលនិងពិន័យអន្តរការណ៍ ស្របតាមច្បាប់

ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម អនុក្រឹត្យលេខ ១០២ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ស្តីពីការពិន័យអន្តរការណ៍ចំពោះបទល្មើសទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**ប្រការ១៨.-**

អ្នកកាន់កាប់អាជ្ញាបណ្ណកាស៊ីណូ និង/ឬប្រតិបត្តិករកាស៊ីណូ ដែលបាននិងកំពុងប្រតិបត្តិការកាស៊ីណូ មុនប្រកាសនេះចូលជាធរមាន ត្រូវមកស្នើសុំអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ តាមបែបបទនិងនីតិវិធី ដូចមានចែងក្នុងប្រកាសនេះ ក្នុងរយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃដែលប្រកាសនេះចូលជាធរមាន។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**ប្រការ១៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២០.-**

អគ្គលេខាធិការ **គ.ល.ក.** អគ្គលេខាធិការរង **គ.ល.ក.** ប្រធាននាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋាននៃ **គ.ល.ក.** អ្នកកាន់កាប់អាជ្ញាបណ្ណកាស៊ីណូ និង/ឬប្រតិបត្តិករកាស៊ីណូ និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៨រោច ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា**

គ.ល.ក

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់សមាសភាពនៃ **គ.ល.ក.**
  "ដើម្បីជូនជ្រាប"
- ដូចប្រការ២០ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ